**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃ
## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង
## និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។

**មាត្រា ២.-**

ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក ត្រូវរៀបចំឱ្យមានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរៀងៗខ្លួន ដើម្បីជួយសិក្សានិងផ្តល់យោបល់ដល់ក្រុមប្រឹក្សានិងគណៈអភិបាលរបស់ខ្លួន លើបញ្ហាទាក់ទងនឹងការងារផែនការ ថវិកា ការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សា ជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងក្រុមប្រឹក្សាប្រភេទផ្សេងទៀត និងបញ្ហាទាក់ទងនឹងមុខងារ ធនធានដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុក។

## ជំពូកទី២
## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
### ផ្នែកទី១
### សមាសភាព និង តួនាទី ភារកិច្ច

**មាត្រា ៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត មានសមាសភាពដូចខាងក្រោម :

- អភិបាលខេត្ត ជាប្រធាន
- អភិបាលរងខេត្ត០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាខេត្ត ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាខេត្តយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅខេត្ត ជាសមាជិក

- នាយកទីចាត់ការទាំងអស់របស់សាលាខេត្ត ជាសមាជិក
- អភិបាលក្រុងនិងអភិបាលស្រុកទាំងអស់នៅក្នុងខេត្ត ជាសមាជិក
- តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូប ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្ត០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ត្រូវស្នើដោយអភិបាលខេត្ត។

តំណាងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត០២រូបត្រូវចាត់តាំងដោយគណៈកម្មាធិការប្រតិបត្តិនៃសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំខេត្ត។ តំណាងទាំងពីររូបនេះត្រូវមានស្ត្រីមួយរូប។

ក្រុមប្រឹក្សាខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត។

**មាត្រា ៤.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត លើកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក. ផែនការអភិវឌ្ឍ និងថវិកា**

- ការដាក់បញ្ចូលផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សាខេត្ត
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគខេត្ត ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ខេត្ត
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគខេត្ត

- រាយការណ៍រីកចម្រើននានាទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាខេត្ត។

**ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្តជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាខេត្ត ជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាខេត្តជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍស្របតាមតម្រូវការរបស់មូលដ្ឋាន។

**គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខេត្ត**

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពខេត្ត
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ទីចាត់ការនានានៃសាលាខេត្ត
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ទីចាត់ការនានានៃសាលាខេត្ត។

**ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងខេត្ត**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ឬ/និងក្រុមប្រឹក្សាស្រុក ឬ/និងក្រុមប្រឹក្សាឃុំ ឬ/និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត។

**ង. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាដែលមាន

ព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត

- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

**ច. ការងារផ្ទេរមុខងារ និងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលខេត្ត
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលខេត្ត
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធានដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលខេត្ត។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

## ផ្នែកទី២
## របៀបរបបការងារ

**មាត្រា ៥.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយនាយករដ្ឋបាលសាលាខេត្ត និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែងនិងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

**មាត្រា ៦.-**

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការ ដែលជានាយករដ្ឋបាលសាលាខេត្ត អភិបាលក្រុង អភិបាលស្រុក ប្រធានមន្ទីរ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ប្រចាំនៅខេត្ត និងនាយកទីចាត់ការនៃសាលាខេត្តអវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

**មាត្រា ៧.-**

អភិបាលខេត្ត អាចស្នើឱ្យអភិបាលរងខេត្ត មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងខេត្ត មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះ អាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

**មាត្រា ៨.-**

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការ ត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន។

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- តម្រូវការរបស់គណៈអភិបាលខេត្ត
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្រប សម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការនិងសំណើដូចខាងលើនេះ អភិបាលខេត្តត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យទីចាត់ការមួយឬច្រើនដែលពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីសិក្សារៀបចំឯកសារ បែបបទ នីតិវិធីនានាតាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាខេត្ត ត្រូវដឹកនាំទីចាត់ការដែលពាក់ព័ន្ធនៅក្នុងសាលាខេត្ត សិក្សារៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយមន្ទីរ អង្គភាព និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

**មាត្រា ៩.-**

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា៨ ខាងលើនេះ

នាយករដ្ឋបាលសាលាខេត្ត ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីកាគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាខេត្តត្រូវដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

**មាត្រា ១០.-**

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ឬដាក់ជូនគណៈអភិបាលខេត្តចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

**មាត្រា ១១.-**

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អាចស្នើសុំបង្កើតអនុគណៈកម្មាធិការឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីអង្គភាពពាក់ព័ន្ធនៃសាលាខេត្ត សាលាក្រុង សាលាស្រុក និងមន្ទីរ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចអំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាខេត្ត ផ្អែកតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

## ជំពូកទី៣
## គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង
### ផ្នែកទី១
### សមាសភាព និង តួនាទី ភារកិច្ច

**មាត្រា ១២.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង មានសមាសភាពដូចខាងក្រោម :

- អភិបាលក្រុង ជាប្រធាន

- អភិបាលរងក្រុង០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាក្រុងយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅក្រុង ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាក្រុង ជាសមាជិក
- ចៅសង្កាត់ទាំងអស់នៅក្នុងក្រុង ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាក្រុង០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង ត្រូវស្នើដោយអភិបាលក្រុង។

ក្រុមប្រឹក្សាក្រុង ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាក្រុង។

**មាត្រា ១៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង លើកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក. ផែនការអភិវឌ្ឍ និងថវិកា**

- ការដាក់បញ្ចូលផែនការអភិវឌ្ឍ និងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ ការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សាក្រុង
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគក្រុង ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ក្រុង

- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគក្រុង
- របាយការណ៍រីកចម្រើននានាទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាក្រុង។

## ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាក្រុងជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ននានា

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាក្រុងជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាក្រុង ជាមួយក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍស្របតាមតម្រូវការរបស់មូលដ្ឋាន។

## គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពក្រុង

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពក្រុង
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ការិយាល័យនានានៃសាលាក្រុង
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ការិយាល័យនានានៃសាលាក្រុង។

## ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាសង្កាត់នៅក្នុងក្រុង។

## ខ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត
- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាក្រុងជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

## ច. ការងារផ្ទេរមុខងារនិងធនធាន

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលក្រុង
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលក្រុង
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលសង្កាត់នៅក្នុងក្រុង
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធានដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលក្រុង។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

# ផ្នែកទី២
# របៀបរបបការងារ

### មាត្រា ១៤.-

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយនាយករដ្ឋបាលសាលាក្រុង និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័ត របៀបរបបការងារជាក់ស្តែង និងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

**មាត្រា ១៥.-**

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការដែលជានាយករដ្ឋបាលសាលក្រុង ចៅសង្កាត់ ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅក្រុង និងប្រធានការិយាល័យរបស់សាលាក្រុង អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួនឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

**មាត្រា ១៦.-**

អភិបាលក្រុង អាចស្នើឱ្យអភិបាលរងក្រុង មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានាចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងក្រុង មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះ អាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

**មាត្រា ១៧.-**

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការ ត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន។

អភិបាលក្រុង ដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- តម្រូវការរបស់គណៈអភិបាលក្រុង
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាក្រុង
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការនិងសំណើដូចខាងលើនេះ អភិបាលក្រុងត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យការិយាល័យមួយឬច្រើនដែលពាក់ព័ន្ធនៃសាលាក្រុង ដើម្បីសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីនានាតាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាក្រុង ត្រូវដឹកនាំការិយាល័យដែលពាក់ព័ន្ធនៅក្នុងសាលាក្រុងសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយការិយាល័យ អង្គភាព នៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅក្រុង និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

**មាត្រា ១៨.-**

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា១៧ខាងលើនេះ នាយករដ្ឋបាលសាលាក្រុង ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីកាគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាក្រុងត្រូវដាក់ជូនអភិបាលក្រុង ដើម្បីពិនិត្យ និងរៀបចំកោះប្រជុំគណៈកម្មាធិការ។

**មាត្រា ១៩.-**

អភិបាលក្រុង ដោយមាននាយករដ្ឋបាលសាលាក្រុងជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាក្រុងចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង ឬដាក់ជូនគណៈអភិបាលក្រុងចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលក្រុង។

**មាត្រា ២០.-**

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អាចស្នើសុំបង្កើតអនុគណៈកម្មាធិការឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីការិយាល័យពាក់ព័ន្ធនៃសាលាក្រុង តំណាងក្រុមប្រឹក្សាសង្កាត់និងការិយាល័យ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សាក្រុង ត្រូវសម្រេចអំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាក្រុង ផ្អែកតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

# ជំពូកទី៤
# គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក
## ផ្នែកទី១
## សមាសភាព និង តួនាទី ភារកិច្ច

**មាត្រា ២១.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក មានសមាសភាពដូចខាងក្រោម :

- អភិបាលស្រុក ជាប្រធាន
- អភិបាលរងស្រុក០១រូប ជាអនុប្រធាន
- នាយករដ្ឋបាលសាលាស្រុក ជាសមាជិកអចិន្ត្រៃយ៍
- សមាជិកក្រុមប្រឹក្សាស្រុកយ៉ាងតិច០២រូប ជាសមាជិក
- ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលដែលប្រចាំនៅស្រុក ជាសមាជិក
- ប្រធានការិយាល័យទាំងអស់របស់សាលាស្រុក ជាសមាជិក
- មេឃុំ ចៅសង្កាត់ទាំងអស់នៅក្នុងស្រុក ជាសមាជិក
- តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាស្រុក ០១រូប ជាសមាជិក

សមាសភាពអនុប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ត្រូវស្នើដោយអភិបាលស្រុក។

ក្រុមប្រឹក្សាស្រុក ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់សមាសភាពប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក។

**មាត្រា ២២.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក លើកិច្ចការសំខាន់ៗដូចខាងក្រោម :

**ក. ផែនការអភិវឌ្ឍនិងថវិកា**

- ការដាក់បញ្ចូលផែនការអភិវឌ្ឍនិងថវិការបស់ក្រសួង ស្ថាប័ន ឬមន្ទីរ ការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាលដែលបានផ្តល់សេវា សម្ភារៈ ឬហេដ្ឋារចនាសម្ព័ន្ធដោយផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ទៅក្នុងផែនការអភិវឌ្ឍ

រយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សា

- សេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងការធ្វើបច្ចុប្បន្នភាព
- សេចក្តីព្រាងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាស្រុក
- សេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងការធ្វើបច្ចុប្បន្នភាព
- ការងារហិរញ្ញវត្ថុនិងថវិការបស់ក្រុមប្រឹក្សាស្រុក
- សេចក្តីព្រាងគម្រោងវិភាជន៍មូលនិធិវិនិយោគស្រុក ដើម្បីគាំទ្រដល់កម្មវិធីនានារបស់ស្រុក
- កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានាដល់គម្រោងវិនិយោគស្រុក
- របាយការណ៍រីកចម្រើននានាទាក់ទងដល់ការងារផែនការអភិវឌ្ឍ កម្មវិធីវិនិយោគ និងថវិការបស់ក្រុមប្រឹក្សាស្រុក។

**ខ. សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ននានា**

- កិច្ចសហប្រតិបត្តិការ ការពិគ្រោះយោបល់ និងការសម្របសម្រួលកិច្ចការនានារបស់ក្រុមប្រឹក្សាស្រុក ជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន
- សម្របសម្រួលការផ្តល់សេវានិងការអភិវឌ្ឍដែលផ្តល់ដោយក្រសួង ស្ថាប័ន ឬដោយមន្ទីរ ការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន ដើម្បីឆ្លើយតបតម្រូវការរបស់មូលដ្ឋាន
- ការសម្របសម្រួលភាពមិនចុះសម្រុងគ្នារវាងកិច្ចការរបស់ក្រុមប្រឹក្សាស្រុក ជាមួយក្រសួង ស្ថាប័ន មន្ទីរ ការិយាល័យ អង្គភាពជំនាញនានា
- ការផ្តល់អនុសាសន៍ដល់ក្រសួង ស្ថាប័ននានា ដើម្បីកែលម្អការផ្តល់សេវា និងការអភិវឌ្ឍស្របតាមតម្រូវការរបស់មូលដ្ឋាន។

**គ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពស្រុក**

- ការរៀបចំយន្តការពិគ្រោះយោបល់និងការចូលរួមក្នុងដំណើរការអនុវត្តការងារនៃរដ្ឋបាលឯកភាពស្រុក
- ការរៀបចំប្រព័ន្ធនិងនីតិវិធីបំពេញការងារ ព្រមទាំងទំនាក់ទំនងរបស់ការិយាល័យនានានៃសាលាស្រុក

- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នាក្នុងការអនុវត្តការងាររបស់ការិយាល័យនានានៃសាលាស្រុក។

**ឃ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុក**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុក
- ការឆ្លើយតបចំពោះអនុសាសន៍ សំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុក ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះមិនអាចដោះស្រាយបាន
- ការដោះស្រាយនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នៅក្នុងស្រុក។

**ង. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត**

- ការរៀបចំយន្តការពិគ្រោះយោបល់រវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត
- ការសម្រុះសម្រួលនូវភាពមិនចុះសម្រុងគ្នារវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាដែលមានព្រំប្រទល់ជាប់គ្នានិងក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត។

**ច. ការងារផ្ទេរមុខងារនិងធនធាន**

- វិធានការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តមុខងារនិងធនធាន
- ការរៀបចំនូវលក្ខណសម្បត្តិនិងមធ្យោបាយដើម្បីទទួលនិងអនុវត្តមុខងារ និងធនធានថ្មីដែលបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលស្រុក
- ការផ្តួចផ្តើមស្នើឡើងនូវមុខងារនិងធនធានដែលគួរត្រូវបានប្រគល់ឬបានធ្វើប្រតិភូកម្មឱ្យរដ្ឋបាលស្រុក
- ការផ្តួចផ្តើមអំពីការធ្វើប្រតិភូកម្មនូវមុខងារនិងធនធានដល់រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់នៅក្នុងស្រុក
- ការវាយតម្លៃលើការអនុវត្តមុខងារនិងធនធានដែលស្ថិតក្រោមការទទួលខុសត្រូវនៃរដ្ឋបាលស្រុក។

ក្រៅពីកិច្ចការខាងលើនេះ គណៈកម្មាធិការអាចទទួលអនុវត្តកិច្ចការផ្សេងទៀត តាមតម្រូវការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន។

## ផ្នែកទី២
## របៀបរបបការងារ

**មាត្រា ២៣.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ត្រូវជួបប្រជុំយ៉ាងតិចពីរខែម្តង។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការទាំងមូល។

សេចក្តីសម្រេចរបស់អង្គប្រជុំអាចយកជាការបាន លុះត្រាមានសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការទាំងមូល។

ប្រធានគណៈកម្មាធិការ ជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយនាយករដ្ឋបាលសាលាស្រុក និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ផ្អែកតាមអនុក្រឹត្យនេះ គណៈកម្មាធិការអាចកំណត់អំពីរបៀបរបបប្រជុំ ការអនុម័តរបៀបរបបការងារជាក់ស្តែង និងការបែងចែកភារកិច្ចដល់សមាជិកគណៈកម្មាធិការតាមការចាំបាច់។

**មាត្រា ២៤.-**

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការដែលជានាយករដ្ឋបាលសាលាស្រុក មេឃុំចៅសង្កាត់ ប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅស្រុក និងប្រធានការិយាល័យរបស់សាលាស្រុក អវត្តមាន សមាជិកនោះអាចចាត់តំណាងដែលមានសិទ្ធិសម្រេចជំនួសខ្លួន ឱ្យចូលរួមប្រជុំគណៈកម្មាធិការបាន។

**មាត្រា ២៥.-**

អភិបាលស្រុក អាចស្នើឱ្យអភិបាលរងស្រុក មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំគណៈកម្មាធិការតាមការចាំបាច់។ អភិបាលរងស្រុក មន្ត្រី ទីប្រឹក្សាបច្ចេកទេស និងអ្នកពាក់ព័ន្ធទាំងនោះ អាចផ្តល់យោបល់នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបាន ប៉ុន្តែពុំមានសិទ្ធិអនុម័តឡើយ។

**មាត្រា ២៦.-**

កិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការ ត្រូវមានរបៀបវារៈដែលបានត្រៀមរៀបចំជាមុន។

អភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការ ត្រូវរៀបចំរបៀបវារៈប្រជុំដោយផ្អែកតាម :

- តម្រូវការរបស់ក្រុមប្រឹក្សាស្រុក
- តម្រូវការរបស់គណៈអភិបាលស្រុក
- តម្រូវការរបស់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក
- សំណើរបស់សមាជិកយ៉ាងតិចមួយភាគបីនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក
- តម្រូវការនៃច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមតម្រូវការ និងសំណើដូចខាងលើនេះ អភិបាលស្រុកត្រូវពិគ្រោះយោបល់នៅក្នុងគណៈអភិបាលរបស់ខ្លួន ចាត់ឱ្យការិយាល័យមួយឬច្រើនដែលពាក់ព័ន្ធនៃសាលាស្រុក ដើម្បីសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីនានាតាមរបៀបវារៈនីមួយៗ។

នាយករដ្ឋបាលសាលាស្រុក ត្រូវដឹកនាំការិយាល័យដែលពាក់ព័ន្ធនៅក្នុងសាលាស្រុក សិក្សា រៀបចំឯកសារ បែបបទ នីតិវិធីខាងលើនេះ ដោយសហការជាមួយការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលប្រចាំនៅស្រុក និងរដ្ឋបាលដែលពាក់ព័ន្ធនានាតាមការចាំបាច់។

**មាត្រា ២៧.-**

ក្នុងការសិក្សា រៀបចំឯកសារ បែបបទ នីតិវិធីដូចមានចែងក្នុងមាត្រា២៦ខាងលើនេះ នាយករដ្ឋបាលសាលាស្រុក ត្រូវផ្អែកតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីកាគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ទាំងនេះ។

ក្រោយពេលរៀបចំឯកសារ បែបបទ នីតិវិធីតាមរបៀបវារៈនីមួយៗរួចហើយ នាយករដ្ឋបាលសាលាស្រុកត្រូវដាក់ជូនអភិបាលស្រុក ដើម្បីពិនិត្យនិងរៀបចំកោះប្រជុំគណៈកម្មាធិការ។

**មាត្រា ២៨.-**

អភិបាលស្រុក ដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការ ដើម្បីដាក់ជូនក្រុមប្រឹក្សាស្រុក ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក ឬដាក់ជូនគណៈអភិបាលស្រុក ចំពោះកិច្ចការទាំងឡាយណាដែលជាសមត្ថកិច្ចរបស់គណៈអភិបាលស្រុក។

**មាត្រា ២៩.-**

ដើម្បីជួយសម្រួលដល់កិច្ចការរបស់ខ្លួន គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក អាចស្នើសុំបង្កើតអនុគណៈកម្មាធិការឬក្រុមការងារតាមការចាំបាច់ ឬតាមតម្រូវ

ការនៃច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

សមាសភាពអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ អាចជ្រើសចេញពីសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រីការិយាល័យពាក់ព័ន្ធនៃសាលាស្រុក តំណាងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងការិយាល័យ អង្គភាពពាក់ព័ន្ធនានាតាមការចាំបាច់។

ក្រុមប្រឹក្សាស្រុក ត្រូវសម្រេចអំពីការបង្កើត ការរៀបចំនិងការប្រព្រឹត្តទៅនៃអនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ។ សេចក្តីសម្រេចនេះ ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាស្រុក ផ្អែកតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

## ជំពូកទី៥

## អំពីការគាំទ្រ

**មាត្រា ៣០.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមអំពីការអនុវត្តតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ដោយផ្អែកតាមស្មារតីនៃអនុក្រឹត្យនេះ។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស មន្ត្រី បុគ្គលិកនៃសាលាខេត្ត សាលាក្រុង សាលាស្រុក ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីធានាដល់ដំណើរការរបស់គណៈកម្មាធិការ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ